**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:......✓..........

# សេចក្តីប្រកាសជូនព័ត៌មាន

នាយកដ្ឋានព័ត៌មាន អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ មានកិត្តិយសសូមជម្រាបជូន សាធារណជនជាតិ និងអន្តរជាតិមេត្តាជ្រាបថា៖ **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នឹងអញ្ជើញធ្វើជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសប្រារព្ធពិធីមិទ្ទីងអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៤ ទិវាបុណ្យឯករាជ្យជាតិ និងទិវាកំណើតកងយោធពលខេមរភូមិន្ទ (៩ វិច្ឆិកា ១៩៥៣-៩ វិច្ឆិកា ២០១៧)។

ពិធីដ៏មហោឡារិក ដែលរៀបចំឡើងដោយក្រសួងការពារជាតិនេះ នឹងប្រព្រឹត្តទៅនាព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅវិទ្យាស្ថានទ័ពជើងគោក (ថ្លុកតាសេក) ខេត្តកំពង់ស្ពឺ ដោយមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន នាយទាហាន ជាមេបញ្ជាការ មេបញ្ជាការរង ពីគ្រប់ស្ថាប័ន កងឯកភាពទូទាំងកងយោធពលខេមរភូមិន្ទ និងសិក្ខាកាមវិទ្យាស្ថានទ័ពជើងគោក ព្រមទាំងមន្ត្រីរាជការ អាជ្ញាធរដែនដីជាច្រើនរូប ពីខេត្តកំពង់ស្ពឺ កំពត និងខេត្តព្រះសីហនុផងដែរ។

សេចក្តីដូចបានប្រកាសជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិ ព្រមទាំងអ្នកសារព័ត៌មានមេត្តាជ្រាបជាព័ត៌មាន៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៧

នាយកដ្ឋានព័ត៌មាន